**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០១៥៦.១៨.អធ.សសរ

# សេចក្តីសម្រេច
# ស្តីពីការបង្កើតក្រុមការងារពង្រឹងយន្តការប្រមូលសួយសារធនធានរ៉ែតាមបណ្តារាជធានី-ខេត្ត

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រប់គ្រង និងធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសអន្តរក្រសួងលេខ ២៨៤ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីអត្រាសួយសារលើតម្លៃធនធានរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ ០០៩៣ រថ.រស.ប្រក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិស្វ័យប្រកាស និងបង់សួយសារលើតម្លៃធនធានរ៉ែដោយសម្បទានិកដែលមានអាជ្ញាប័ណ្ណអាជីវកម្មរ៉ែ និងការដ្ឋានវាយថ្ម សម្រាប់ការធ្វើអាជីវកម្មរ៉ែសំណង់។

- បានឃើញសេចក្តីសម្រេចលេខ ០០៩៦ រថ.អកទទ.សសរ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការចាត់តាំងថ្នាក់ដឹកនាំដើម្បីទទួលខុសត្រូវក្នុងការតាមដាន ការកត់ត្រា ការកៀរគរចំណូល និងចាត់វិធានការទារបំណុល
- យោងតាមការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល

## សម្រេច

**ប្រការ ១៖** បង្កើតក្រុមការងារចុះពង្រឹងយន្តការប្រមូលសួយសារធនធានរ៉ែតាមបណ្តារាជធានី-ខេត្ត ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | លោក ប៉េង ណាវុធ | អគ្គនាយករងធនធានរ៉ែ | ប្រធាន |
| ២- | លោក អ៊ឹង ឌីប៉ូឡា | អគ្គនាយករងកិច្ចការទូទៅ | អនុប្រធាន |
| ៣- | លោក ហុង បូណា | អនុប្រធាននាយកដ្ឋានរ៉ែសំណង់ | អនុប្រធាន |
| ៤- | លោក ហ៊ីង ទន់ | អនុប្រធាននាយកដ្ឋានរ៉ែសំណង់ | សមាជិក |
| ៥- | លោក យិន រដ្ឋា | អនុប្រធាននាយកដ្ឋានអាជីវកម្មរ៉ែ | សមាជិក |
| ៦- | លោក ហ៊ីង សារឿន | អនុប្រធាននាយកដ្ឋានជំរុញនិងអភិវឌ្ឍធនធានរ៉ែ | សមាជិក |
| ៧- | លោក អៀង វណ្ណារិទ្ធ | ប្រធានការិយាល័យនាយកដ្ឋានរ៉ែសំណង់ | សមាជិក |
| ៨- | លោក ស៊ូ ភីរៈ | មន្ត្រីនាយកដ្ឋានអាជីវកម្មរ៉ែ | សមាជិក |
| ៩- | លោក ឌុច សំអាន | មន្ត្រីអគ្គាធិការដ្ឋាន | សមាជិក |

**ប្រការ ២៖** ក្រុមការងារខាងលើមានភារកិច្ច៖

- ពង្រឹងសមត្ថភាពស្ថាប័នកិច្ចរបស់មន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ដើម្បីគ្រប់គ្រង និងប្រមូលចំណូលសួយសាររ៉ែ
- ត្រួតពិនិត្យ និងអធិការកិច្ច លើការងារប្រមូលចំណូលសួយសាររ៉ែរបស់មន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត
- ចុះផ្សព្វផ្សាយ និងណែនាំដល់អាជីវករ/ក្រុមហ៊ុនរ៉ែ អំពីការអនុវត្តប្រកាសអន្តរក្រសួង លេខ ២៨៤ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីអត្រាសួយសារលើតម្លៃធនធានរ៉ែ និងនិតិវិធីនៃការបង់ថ្លៃសួយសារ
- ចុះផ្សព្វផ្សាយ និងណែនាំដល់អាជីវករ/ក្រុមហ៊ុនរ៉ែ អំពីការអនុវត្តប្រកាសលេខ ០០៩៣ រថ.រស.ប្រក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីស្វ័យប្រកាស និងបង់សួយសារលើតម្លៃធនធានរ៉ែ ដោយសម្បទានិកដែលមានអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ការធ្វើអាជីវកម្មរ៉ែសំណង់។

ជាជំនួយការ ឯកឧត្តម ម៉េង សក្តិធារ៉ា រដ្ឋលេខាក្រសួងរ៉ែ និងថាមពល ក្នុងការអនុវត្ត សេចក្តីសម្រេចលេខ ០០៩៦ រថ.អកទទ.សសរ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការចាត់តាំងថ្នាក់ដឹកនាំដើម្បីទទួលខុសត្រូវក្នុងការតាមដាន ការកត់ត្រា ការកៀរគរចំណូល និងចាត់វិធានការទារបំណុល។

**ប្រការ ៣៖** នាយកខុទ្ទកាល័យ អគ្គនាយកធនធានរ៉ែ អគ្គនាយកកិច្ចការទូទៅ អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត និងសាម៉ីជនដូចមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះ។

**ប្រការ ៤៖** សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ក្រសួងរ៉ែ និងថាមពល

**ស៊ុយ_សែម**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលារាជធានី-ខេត្ត

-មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត

-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត

-សាម៉ីជន។ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ